## ៨-២ បុណ្យពុទ្ធសាសនា

បុណ្យពុទ្ធសាសនាដែលគេរាប់ថាជាបុណ្យប្រចាំឆ្នាំ គឺៈ បុណ្យមាឃបូជា បុណ្យវិសាខបូជា បុណ្យចូលវស្សា បុណ្យចេញវស្សា និង បុណ្យកឋិន ។

បុណ្យចូលឆ្នាំ និង បុណ្យភ្ជុំបិណ្ឌ ជាបុណ្យជាតិភ្ជាប់ នឹង សាសនា ។

### ៨-២-១ បុណ្យមាឃបូជា

បុណ្យមាឃបូជា គេធ្វើនៅថ្ងៃពេញបូណ៌មីខែមាឃ ដើម្បីរំលឹកនូវការជួបជុំនៃព្រះសង្ឃដ៏ច្រើនៗ បុណ្យនេះ ប្រកប ដោយអង្គ៤ (ហៅថា ចតុរង្គសន្និបាត) គឺ :

១-ថ្ងៃពេញបូណ៌មីខែមាឃ

២-ព្រះសង្ឃចំនួន ១២៥០អង្គ បានមកជួជុំគ្នា ដោយមិនមាន នរណានិមន្តឬបានណាត់គ្នាទុកជាមុនទេ

៣-ព្រះសង្ឃទាំង ១២៥០ អង្គនេះ សុទ្ធតែជា ឯហិភិក្ខុគឺបានបួសដោយវិធីដែលព្រះពុទ្ធលោកគ្រាន់តែថា “អ្នកចូរមកជាភិក្ខុចុះ” ប៉ុណ្ណោះក៏ជាការស្រេច មិនបាច់មានគ្រូសូត្រទេ

៤-ព្រះសង្ឃចំនួន ១២៥០ អង្គនេះ សុទ្ធតែជាព្រះខីណាស្រព គឺអស់កិលេសបានសម្រេចអរហត្តផល និងអភិញ្ញា មានឫទ្ធានុភាពច្រើន ។

ចតុរង្គសន្និបាតនោះកើតឡើង ក្នុងវត្តវេឡុវ័ន ក្រុងរាជគ្រឹះ ក្រោយពេលដែលព្រះពុទ្ធបានត្រាស់ដឹងហើយ ៩ខែ ។

សន្និបាតបែបនោះ មានតែម្តងប៉ុណ្ណោះ ក្នុងសន្និបាតនោះ ព្រះពុទ្ធបានបំពេញកិច្ច២គឺសម្តែងឱវាទបាតិមោក្ខ នឹង តែងតាំងព្រះអគ្គសាវក ។

*<u>ក-ឱវាទបាតិមោក្ខ</u> មានគោល ៣ គឺ :*

*១-ការឈប់ធ្វើអំពើអាក្រក់គ្រប់យ៉ាង*

*២-ការខំធ្វើអំពើល្អឲ្យច្រើនឡើង ៗ*

*៣-ការសំអាតចិត្តរបស់ខ្លួនឲ្យស្អាតផូរផង់ ។*

*នេះជាសេចក្តីសង្ខេបនៃពាក្យ ប្រៀនប្រដៅរបស់ ព្រះពុទ្ធ ។ល។*

*<u>ខ-ការតែងតាំងអគ្គសាវក</u>*

*១-ព្រះសារីបុត្រ ដែលមានបញ្ញាច្រើន ជាអគ្គសាវកស្តាំ*

*២-ព្រះមោគ្គល្លាន ដែលមានឫទ្ធិច្រើន ជាអគ្គសាវកឆ្វេង។*

*ក្រៅពីនេះ គឺនៅថ្ងៃពេញបូណ៌មីខែមាឃនេះដែរ តែឆ្នាំចុងក្រោយបំផុត មានហេតុការណ៍មួយទៀត គឺការដាក់បង់នូវអាយុសង្ខារ កំណត់ថ្ងៃចូលបរិនិព្វាន។*

*ព្រះដ៏ទ្រង់ញាណបានសម្រេចថា :*

*“**អំណើះពីនេះទៅតែ ៣ ខែទៀតទេ តថាគត នឹងបរិនិព្វាន ហើយ**” ។*

*មាឃបូជា គេធ្វើដើម្បីរំលឹក នូវហេតុការណ៍ដូចបានជម្រាបមកខាងលើនេះ ។*

*វិលទៅរកទំព័រចាស់វិញ ដោយចុចលើព្រួញ “ ← “ ដែលនៅ កៀនកញ្ចក់ ខាងលើ និងខាងឆ្វេង។*